ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ៣៥ អយក.សណន

# សេចក្តីណែនាំ
# ស្តីពី
# ការប្រើប្រាស់ថវិកាឧបត្ថម្ភកម្មវិធីប្រឹក្សាគរុកោសល្យ
# សម្រាប់ទីប្រឹក្សាគរុកោសល្យជំនាញតាមកម្រង និងទីប្រឹក្សាគរុកោសល្យប្រចាំសាលារៀន

ក្រសួងអប់រំ យុវជន និងកីឡាបានអនុម័តដាក់ឱ្យអនុវត្តគោលនយោបាយស្តីពីកម្រងសាលារៀន និងឯកសារប្រតិបត្តិ នាថ្ងៃទី១៨ ខែមករា ឆ្នាំ២០១០។ ជាបន្តបន្ទាប់ កម្រងសាលារៀនត្រូវបានបង្កើតឡើង តាមការណែនាំ ដែលមានប្រភេទជាកម្រងទីប្រជុំជន កម្រងធម្មតា កម្រងមិនធម្មតា និងកម្រងដាច់ស្រយាល។ ជាងនេះទៅទៀត ការបង្កើតកម្រងសាលារៀន មានអត្ថប្រយោជន៍ ផ្នែករដ្ឋបាល ផ្នែកគរុកោសល្យ ផ្នែកសេដ្ឋកិច្ច និងផ្នែកសហគមន៍ និងគាំទ្រដល់ការអនុវត្តកម្មវិធីសាលាកុមារមេត្រី។ ចំនួនកម្រងសាលារៀនបឋមសិក្សាបានកើនឡើងជាបន្តបន្ទាប់ ដោយនៅឆ្នាំសិក្សា២០១៤-២០១៥ មានកម្រងសាលារៀនសរុប ១ ២២៥ ឆ្នាំសិក្សា២០២០-២០២១ មាន ១ ២៧៣ និងឆ្នាំសិក្សា២០២១-២០២២ មាន ១ ៣៤២ ដែលជាមធ្យមក្នុងមួយកម្រងសាលារៀន មានសាលាបឋមសិក្សាប្រមាណ ៥,៤៤។

ម្យ៉ាងវិញទៀត ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ ក្រសួងអប់រំ យុវជន និងកីឡាបានកៀរគរថវិកាពីអង្គការដៃគូអភិវឌ្ឍន៍នានា ដើម្បីបណ្តុះបណ្តាលគ្រូបង្រៀនថ្នាក់ទី១ និងទី២ លើការអនុវត្តកញ្ចប់សម្ភារៈអំណាន និងគណិតវិទ្យាថ្នាក់ដំបូង។ រហូតមកដល់ឆ្នាំសិក្សា២០២២-២០២៣ កញ្ចប់សម្ភារៈអំណាននិងគណិតវិទ្យាថ្នាក់ទី១ ទី២ និងទី៣ បាននិងកំពុងអនុវត្តនៅក្នុងសាលាបឋមសិក្សាប្រមាណ ២៨% នៅទូទាំងប្រទេស ហើយគ្រោងនឹងពង្រីកការអនុវត្តឱ្យបានទូទាំងប្រទេសនាពេលខាងមុខ។ ទន្ទឹមនឹងការអនុវត្តកញ្ចប់សម្ភារៈអំណាន និងគណិតវិទ្យាថ្នាក់ដំបូង ការចុះគាំទ្រតាមរយៈកម្មវិធីប្រឹក្សាគរុកោសល្យ (Mentoring Programme) បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការគាំទ្រនិងជំរុញការអនុវត្តរបស់គ្រូបង្រៀន។ រហូតមកដល់ពេលនេះ ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនកម្រិតថ្នាក់ដំបូង និងការផ្តល់ប្រឹក្សាគរុកោសល្យ សុទ្ធតែទទួលបានការគាំទ្រមូលនិធិពីអង្គការដៃគូអភិវឌ្ឍ និងគម្រោងនានារបស់ក្រសួង។

តាមរយៈអង្គការយូនីសេហ្វ (UNICEF) ក្រោមមូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាពវិស័យអប់រំ (CDPF) បានចាត់ទុកការបណ្តុះបណ្តាលគ្រូបង្រៀនថ្នាក់ទី១ និងទី២ លើការអនុវត្តកញ្ចប់សម្ភារៈអំណាន និងគណិតវិទ្យាថ្នាក់ដំបូងជាអាទិភាព។ ក្នុងន័យនេះ ដើម្បីលើកកម្ពស់អភិវឌ្ឍសមត្ថភាពគ្រូបង្រៀនកម្រិតថ្នាក់ដំបូង អង្គការUNICEF នឹងគាំទ្រដល់កម្មវិធីប្រឹក្សាគរុកោសល្យ តាមរយៈការផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុដល់ទីប្រឹក្សា



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

គរុកោសល្យជំនាញតាមកម្រង និងទីប្រឹក្សាគរុកោសល្យប្រចាំសាលារៀន ដើម្បី ៖

- លើកកម្ពស់ការអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន នៅកម្រិតបឋមសិក្សា
- លើកកម្ពស់គុណភាពការបង្រៀននិងរៀនឱ្យមានភាពប្រហាក់ប្រហែលគ្នារវាងសាលារៀននៅទីប្រជុំជន តំបន់ជួបការលំបាក និងតំបន់ដាច់ស្រយាល
- គាំទ្រដល់សកម្មភាពផ្តល់ប្រឹក្សាគរុកោសល្យ ឈានទៅលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។

## I. ភារកិច្ច និងការទទួលខុសត្រូវ

### ១. ទីប្រឹក្សាគរុកោសល្យជំនាញតាមកម្រង និងទីប្រឹក្សាគរុកោសល្យប្រចាំសាលារៀន

ភារកិច្ច និងការទទួលខុសត្រូវរបស់ទីប្រឹក្សាគរុកោសល្យជំនាញតាមកម្រង និងទីប្រឹក្សាគរុកោសល្យប្រចាំសាលារៀន ត្រូវអនុវត្តតាមសៀវភៅណែនាំប្រតិបត្តិស្តីពីការប្រឹក្សាគរុកោសល្យកម្រិតថ្នាក់ដំបូង របស់ក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២០។

### ២. សាលាបឋមសិក្សា

- ពិនិត្យផែនការសកម្មភាពទីប្រឹក្សាគរុកោសល្យប្រចាំសាលារៀនរបស់ខ្លួន
- ចេញលិខិតឧទ្ទេសនាម ឬលិខិតបង្គាប់ការ ជូនទីប្រឹក្សាគរុកោសល្យប្រចាំសាលារៀន ដើម្បីចុះផ្តល់ប្រឹក្សាគរុកោសល្យ
- ចូលរួមពិនិត្យតាមដានដំណើរការអនុវត្តកញ្ចប់សម្ភារៈអំណាននិងគណិតវិទ្យាថ្នាក់ដំបូង និងកម្មវិធីប្រឹក្សាគរុកោសល្យ
- សហការជាមួយទីប្រឹក្សាគរុកោសល្យជំនាញ ក្នុងការកែលម្អនិងលើកកម្ពស់ការអនុវត្តភារកិច្ចរបស់ទីប្រឹក្សាគរុកោសល្យប្រចាំសាលារៀន។

### ៣. សាលាបង្គោល (សាលាបឋមសិក្សាដែលនាយកជាប្រធានកម្រង)

- ពិនិត្យផែនការសកម្មភាពរបស់ទីប្រឹក្សាគរុកោសល្យជំនាញតាមកម្រង និងទីប្រឹក្សាគរុកោសល្យប្រចាំសាលារៀន នៅក្នុងកម្រងរបស់ខ្លួន
- ពិនិត្យ និងរៀបចំបើកផ្តល់ថវិកាជូនទីប្រឹក្សាគរុកោសល្យជំនាញតាមកម្រង និងទីប្រឹក្សាគរុកោសល្យប្រចាំសាលារៀន ដោយផ្អែកតាមសំណើសុំថវិកា ភ្ជាប់មកជាមួយនូវ ផែនការសកម្មភាព លិខិតឧទ្ទេសនាម ឬ លិខិតបង្គាប់ការ និងឧបករណ៍សង្កេតការបង្រៀន
- ចេញលិខិតឧទ្ទេសនាម ឬលិខិតបង្គាប់ការ ជូនទីប្រឹក្សាគរុកោសល្យជំនាញតាមកម្រង
- បូកសរុបរបាយការណ៍លទ្ធផលអនុវត្តកម្មវិធីប្រឹក្សាគរុកោសល្យ តាមប្រព័ន្ធរបាយការណ៍ KOBO
- បូករបាយការណ៍ទូទាត់ចំណាយ ផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាល ក្រុង ស្រុក នៅសប្តាហ៍ទី១ នៃខែធ្នូ ឆ្នាំ២០២៣។

### ៤. ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក

- បូកសរុបផែនការសកម្មភាព របាយការណ៍លទ្ធផល និងរបាយការណ៍ចំណាយថវិកា របស់ទីប្រឹក្សាគរុកោសល្យជំនាញតាមកម្រង និងទីប្រឹក្សាគរុកោសល្យប្រចាំសាលារៀន បញ្ជូនទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត

- ពិនិត្យ និងបូកសរុបរបាយការណ៍ចំណាយថវិកាពីសាលាបង្គោល រួចបញ្ជូនទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត យ៉ាងយូរនៅដើមសប្តាហ៍ទី២ នៃខែធ្នូ ឆ្នាំ២០២៣
- ចូលរួមពិនិត្យតាមដានការអនុវត្តកម្មវិធីប្រឹក្សាគរុកោសល្យ។

**៥. មន្ទីរអប់រំ យុវជន និងកីឡាខេត្ត**

**៥.១- ការិយាល័យបឋមសិក្សា**

- ពិនិត្យ និងបូកសរុបបញ្ជីកម្រងសាលារៀន និងសាលាបង្គោល ព្រមទាំងលេខនិងឈ្មោះគណនីរបស់សាលាបង្គោលនីមួយៗ ផ្ញើជូននាយកដ្ឋានបឋមសិក្សា
- សហការ ពិនិត្យភាពត្រឹមត្រូវ ឈ្មោះនិងលេខគណនី របស់សាលាបង្គោល ជាមួយការិយាល័យគណនេយ្យ សម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ
- បូកសរុបផែនការសកម្មភាព និងរបាយការណ៍លទ្ធផល ផ្ញើជូននាយកដ្ឋានបឋមសិក្សា នៅសប្តាហ៍ទី៣ នៃខែធ្នូ ឆ្នាំ២០២៣
- ផ្តល់ការគាំទ្រការអនុវត្តកម្មវិធីប្រឹក្សាគរុកោសល្យ។

**៥.២- ការិយាល័យគណនេយ្យ សម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ**

- សហការ ពិនិត្យភាពត្រឹមត្រូវ ឈ្មោះនិងលេខគណនី របស់សាលាបង្គោល ជាមួយការិយាល័យបឋមសិក្សា
- ពិនិត្យភាពត្រឹមត្រូវ និងបូកសរុបរបាយការណ៍ចំណាយពីការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក រួចបញ្ជូនទៅនាយកដ្ឋានហិរញ្ញវត្ថុ នៅសប្តាហ៍ទី៣ នៃខែធ្នូ ឆ្នាំ២០២៣
- ផ្តល់ការគាំទ្រការអនុវត្តកម្មវិធីប្រឹក្សាគរុកោសល្យ។

**៦. នាយកដ្ឋានបឋមសិក្សា**

- ផ្តល់វគ្គបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធស្តីពីការអនុវត្តកម្មវិធីប្រឹក្សាគរុកោសល្យ ក្រោមមូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាពវិស័យអប់រំ (CDPF)
- រៀបចំបូកសរុប បញ្ជីកម្រងសាលារៀន សាលាបង្គោល ចំនួនទីប្រឹក្សាគរុកោសល្យជំនាញ និងទីប្រឹក្សាគរុកោសល្យប្រចាំសាលារៀន រួចផ្ញើជូននាយកដ្ឋានហិរញ្ញវត្ថុ ដើម្បីរៀបចំសំណើសុំថវិកាទៅអង្គការ UNICEF
- បូកសរុបរបាយការណ៍លទ្ធផលកម្មវិធីប្រឹក្សាគរុកោសល្យ តាមរយៈរបាយការណ៍បូកសរុបលទ្ធផលសរុបរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត(ការិយាល័យបឋមសិក្សា)/ប្រព័ន្ធរបាយការណ៍ KOBO
- រៀបចំរបាយការណ៍ទូទាត់ ដាក់ជូនទៅនាយកដ្ឋានហិរញ្ញវត្ថុ ដើម្បីស្នើសុំទូទាត់ទៅអង្គការ UNICEF នៅសប្តាហ៍ទី៤ ខែធ្នូ ឆ្នាំ២០២៣
- ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីប្រឹក្សាគរុកោសល្យ។

**៧. នាយកដ្ឋានហិរញ្ញវត្ថុ**

- រៀបចំស្នើសុំថវិកាសម្រាប់កម្មវិធីប្រឹក្សាគរុកោសល្យ ទៅអង្គការ UNICEF
- រៀបចំលិខិតជូនដំណឹងទៅអង្គការ UNICEF រយៈពេលយ៉ាងយូរ ១សប្តាហ៍ បន្ទាប់ពីថវិកាចូលគណនីរបស់ក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានហិរញ្ញវត្ថុ)

- ពិនិត្យភាពត្រឹមត្រូវនៃព័ត៌មានគណនីរបស់សាលាបង្គោល ដែលត្រូវផ្ទេរថវិកាជូន
- រៀបចំផ្ទេរថវិកាឧបត្ថម្ភកម្មវិធីប្រឹក្សាគរុកោសល្យទៅតាមសាលាបង្គោល ដើម្បីអនុវត្តសកម្មភាព
- រៀបចំលិខិតជូនដំណឹងទៅអង្គការ UNICEF អំពីថវិកាដែលបានផ្ទេរចូលគណនីរបស់សាលាបង្គោល
- កត់ត្រាកិច្ចបញ្ជិកាគណនេយ្យមួយដោយឡែក សម្រាប់ប្រាក់ឧបត្ថម្ភកម្មវិធីនេះ
- ពិនិត្យរបាយការណ៍ទូទាត់ដែលផ្តល់ដោយនាយកដ្ឋានបឋមសិក្សា
- ពិនិត្យភាពត្រឹមត្រូវនៃទិន្នន័យ និងរៀបចំបែបបទស្នើសុំផ្ទេរថវិកាដែលនៅសល់ ជូនទៅអង្គការ UNICEF វិញ (ប្រសិនបើមាន)
- រៀបចំឯកសារទូទាត់ទៅអង្គការ UNICEF នៅសប្តាហ៍ទី៤ នៃខែធ្នូ ឆ្នាំ២០២៣
- ចូលរួមពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីប្រឹក្សាគរុកោសល្យ។

## II. **ការគ្រប់គ្រងថវិកា**

ការរៀបចំផែនការថវិកា និងការអនុវត្តថវិកា សម្រាប់កម្មវិធីប្រឹក្សាគរុកោសល្យជំនាញ ក្រោមមូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាពវិស័យអប់រំ(CDPF)នេះ ត្រូវអនុវត្តតាមនីតិវិធីគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ(SOF) របស់ក្រសួងអប់រំ យុវជន និងកីឡាឆ្នាំ២០១៨ ។

### ១. **ការរៀបចំថវិកា**

#### ១.១- វិសាលភាព

សម្រាប់ឆ្នាំ ២០២៣ ថវិកាគាំទ្រនេះ ត្រូវផ្តល់ជូនទីប្រឹក្សាគរុកោសល្យជំនាញតាមកម្រង និងទីប្រឹក្សាគរុកោសល្យប្រចាំសាលារៀន នៅខេត្តចំនួន ១២ រួមមាន៖ ខេត្តកោះកុង បន្ទាយមានជ័យ ប៉ៃលិន ព្រះសីហនុ មណ្ឌលគិរី រតនៈគិរី ពោធិ៍សាត់ កំពង់ស្ពឺ ស្ទឹងត្រែង ឧត្តរមានជ័យ ក្រចេះ និងខេត្តព្រះវិហារ។

#### ១.២- គោលដៅនៃការផ្តល់ជូន

ប្រាក់ឧបត្ថម្ភផ្តល់ជូនទីប្រឹក្សាគរុកោសល្យជំនាញតាមកម្រង និងទីប្រឹក្សាគរុកោសល្យប្រចាំសាលារៀននៃខេត្តគោលដៅទាំង១២ សម្រាប់ទីប្រឹក្សាគរុកោសល្យជំនាញនៅតាមកម្រង និងប្រឹក្សាគរុកោសល្យប្រចាំសាលារៀន ចុះបំពេញការងារប្រឹក្សាគរុកោសល្យនៅតាមសាលារៀន។

#### ១.៣- គោលការណ៍ឧបត្ថម្ភ

- ទីប្រឹក្សាគរុកោសល្យជំនាញតាមកម្រង ដែលធ្វើដំណើរចុះផ្តល់ប្រឹក្សាគរុកោសល្យដល់ទីប្រឹក្សាគរុកោសល្យប្រចាំសាលារៀន នឹងទទួលបានថវិកាឧបត្ថម្ភចំនួន ២០.០០០ (ម្ភៃពាន់)រៀល ក្នុងមួយនាក់ ក្នុងមួយដង
- ទីប្រឹក្សាគរុកោសល្យប្រចាំសាលារៀន ដែលចុះផ្តល់ប្រឹក្សាគរុកោសល្យដល់គ្រូបង្រៀនថ្នាក់ទី១ និង/ឬ ថ្នាក់ទី២ នឹងទទួលបានថវិកាឧបត្ថម្ភចំនួន ១០.០០០ (ដប់ពាន់)រៀល ក្នុងមួយនាក់ ក្នុងមួយដង។

#### ១.៤- គណនេយ្យភាពថវិកា

នៅពេលបានទទួលសាច់ប្រាក់ គ្រប់សាលាបឋមសិក្សាបង្គោលទាំង៤១១សាលា បិទផ្សាយលើបញ្ជរព័ត៌មាន ជូនលោកគ្រូ អ្នកគ្រូ គណៈកម្មការគ្រប់គ្រងសាលារៀន និងអ្នកពាក់ព័ន្ធ ជាពិសេស

ទីប្រឹក្សាគរុកោសល្យជំនាញ និងទីប្រឹក្សាគរុកោសល្យប្រចាំសាលារៀន នូវព័ត៌មានដូចខាងក្រោម៖

- ចំនួនសាច់ប្រាក់ដែលបានទទួល
- គម្រោងចំណាយសម្រាប់អនុវត្តសកម្មភាព

គណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ និងគណៈកម្មការគ្រប់គ្រងសាលារៀន ត្រូវសហការចាត់ចែង គ្រប់គ្រង និងទទួលខុសត្រូវលើការចំណាយថវិកា។

## ២. ការអនុវត្តថវិកា

ការអនុវត្តថវិកា ត្រូវចាប់ផ្តើមនៅពេលមានសាច់ប្រាក់ចូលក្នុងគណនីធនាគាររបស់សាលារៀន។ ចំពោះសាច់ប្រាក់នៅសល់ចុងឆ្នាំ ត្រូវបង្វែរត្រឡប់មកគណនីរបស់ក្រសួងអប់រំ យុវជន និងកីឡា(នាយកដ្ឋានហិរញ្ញវត្ថុ) តាមរយៈលេខគណនី ០០០០០០០១៣៩០៧ និងឈ្មោះគណនី Finance Dept (MEYS): Other Expenses វិញ ដើម្បីក្រសួងមានមូលដ្ឋានបូកសរុបថវិកា បង្វែរជូនអង្គការ UNICEF ។

### ២.១- ការស្នើសុំថវិកាទៅអង្គការ UNICEF

ផ្អែកតាមសំណើរបស់នាយកដ្ឋានបឋមសិក្សា នាយកដ្ឋានហិរញ្ញវត្ថុត្រូវរៀបចំស្នើសុំថវិកាទៅអង្គការ UNICEF។ អង្គការ UNICEF នៅពេលអនុម័តរួច នឹងផ្ទេរថវិកាចូលមកគណនីរបស់ក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានហិរញ្ញវត្ថុ) ជាប្រាក់រៀល នៅធនាគារជាតិនៃកម្ពុជា។

### ២.២- ការផ្ទេរថវិកាពីនាយកដ្ឋានហិរញ្ញវត្ថុ ទៅកម្រងសាលារៀនសាធារណៈ

នៅពេលទទួលបានថវិកាពីអង្គការ UNICEF រយៈពេលយ៉ាងយូរ ២សប្តាហ៍បន្ទាប់ នាយកដ្ឋានហិរញ្ញវត្ថុត្រូវរៀបចំឯកសារ ដើម្បីស្នើសុំផ្ទេរថវិកាពីគណនីរបស់ក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានហិរញ្ញវត្ថុ) ជូនកម្រងសាលារៀនទាំង ៤១១ ក្នុងខេត្តទាំង១២ តាមរយៈគណនីធនាគាររបស់សាលាបង្គោលដែលមានស្រាប់ ជាប្រាក់រៀល។ ការផ្ទេរសាច់ប្រាក់ចូលទៅគណនីមូលនិធិដំណើរការសាលារៀនសាធារណៈនេះ ធ្វើឡើងតែមួយលើកគត់ ក្នុងត្រីមាសទី៣ ឆ្នាំ២០២៣ រីឯថ្លៃសេវាផ្ទេរប្រាក់ ជាបន្ទុករបស់មូលនិធិភាពជាដៃគូសម្រាប់ការអភិវឌ្ឍន៍សមត្ថភាពវិស័យអប់រំ(CDPF)។

### ២.៣- កិច្ចបញ្ជិកាគណនេយ្យ

សាលារៀនត្រូវកត់ត្រាប្រតិបត្តិការថវិកាប្រចាំឆ្នាំ សាច់ប្រាក់ចូលគណនីធនាគារ ចំណូល ចំណាយ បង្វែរសាច់ប្រាក់នៅសល់ ។ល។ នៅក្នុងសកម្មភាពគោល "២. កែលម្អគុណភាពអប់រំ" សកម្មភាព "២.២ សម្ភាររៀននិងបង្រៀន" និងប្រភពថវិកា "មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍន៍សមត្ថភាពវិស័យអប់រំ (CDPF)" នៅក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា(EFMS) លើមុខងារគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ(SOF) សម្រាប់សាលារៀនដែលមានប្រព័ន្ធអ៊ីនធើណែត និងដែលបានកត់ត្រាប្រតិបត្តិការឆ្នាំ២០២៣ ទាំងអស់នៅក្នុងប្រព័ន្ធEFMS ឬប្រព័ន្ធរបាយការណ៍គ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ(Advanced Excel) សម្រាប់សាលារៀនដែលមិនមានអ៊ីនធើណែត និងដែលបានកត់ត្រាប្រតិបត្តិការឆ្នាំ២០២៣ ទាំងអស់នៅក្នុងប្រព័ន្ធរបាយការណ៍ Advanced Excel។

### ៣.៣- សក្ខីបត្រទូទាត់ចំណាយថវិកា

ត្រូវអនុវត្តតាមនីតិវិធីគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ(SOF)៖

- ហេរញ្ញិកសាលាត្រូវប្រមូលឯកសារ លិខិតយុត្តិការ និងសក្ខីបត្រចំណាយ រួមមាន៖
  - លិខិតស្នើសុំថវិការបស់ទីប្រឹក្សាគរុកោសល្យជំនាញតាមកម្រង និងទីប្រឹក្សាគរុកោសល្យប្រចាំសាលារៀន
  - សក្ខីបត្រចំណាយ រួមមាន៖ ១) ផែនការសកម្មភាព ២) លិខិតឧទ្ទេសនាម ឬបង្គាប់ការ និង ៣) ឧបករណ៍សង្កេតការបង្រៀន
  - បណ្ណចំណាយ
- ហេរញ្ញិកសាលាត្រូវរៀបចំរបាយការណ៍ចំណាយថវិកា សក្ខីបត្រចំណាយ លិខិតយុត្តិការ ឯកសារច្បាប់ដើមពាក់ព័ន្ធផ្សេងៗ និងកិច្ចបញ្ជិកាគណនេយ្យ ដោយត្រូវរក្សាទុកនៅអង្គភាពសាមីដើម្បីជាកម្មវត្ថុនៃការធ្វើសវនកម្មក្រោយចំណាយ។

ទទួលបានសេចក្តីណែនាំនេះ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត កោះកុង បន្ទាយមានជ័យ ប៉ៃលិន ព្រះសីហនុ មណ្ឌលគិរី រតនៈគិរី ពោធិ៍សាត់ កំពង់ស្ពឺ ស្ទឹងត្រែង ឧត្តរមានជ័យ ក្រចេះ និងខេត្តព្រះវិហារ ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក គណៈគ្រប់គ្រងសាលាបង្គោល ត្រូវចូលរួមអនុវត្តប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

ថ្ងៃព្រហស្បតិ៍ ២រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែសីហា ឆ្នាំ ២០២៣

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

**កន្លែងទទួល៖**

- សាលាខេត្តកោះកុង បន្ទាយមានជ័យ ប៉ៃលិន ព្រះសីហនុ មណ្ឌលគិរី រតនៈគិរី ពោធិ៍សាត់ កំពង់ស្ពឺ ស្ទឹងត្រែង ឧត្តរមានជ័យ ក្រចេះ និងខេត្តព្រះវិហារ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា
- អង្គការUnicef ប្រចាំនៅកម្ពុជា

**"ដើម្បីជ្រាបជាព័ត៌មាន"**

- កាលប្បវត្តិ
- ឯកសារ-នាយកដ្ឋានហិរញ្ញវត្ថុ